**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៤៦០
ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣
**<u>សាលដីកា</u>**
លេខៈ១៧២
ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............. ជាប្រធាន
២-លោក ............... ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ................. ជាចៅក្រមរបាយការណ៍
៥-លោក .............. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**
-លោក ...............

**<u>តំណាងមហាអយ្យការ</u>**
-លោក ................ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៧៦(ង) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៥៧ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាងៈ

ដើមចោទឈ្មោះឡូហល (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៦ឆ្នាំជាតិខ្មែរឥស្លាម ទីលំនៅផ្ទះលេខ១៣៥ ភូមិ៤ សង្កាត់ច្រាំងចំរះ១ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះឡោះ ម៉ាន(ស) ម្តាយឈ្មោះស្លេះ ខ(ស) ប្រពន្ធឈ្មោះតូនីសំរ៉ស់ មានកូន០៤នាក់។

**មានមេធាវីលោក ............ ។**

ចុងចម្លើយឈ្មោះរស (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ២៣២ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះកូប រូន(រ) ម្តាយឈ្មោះទាំ ផះ(រ) ប្រពន្ធឈ្មោះសាន ភ័ស មានកូន០៨នាក់ ។ ផ្ទេរសិទ្ធិឱ្យតំណាងឈ្មោះសាត ហៀក ជាកូន ។

**<u>កម្មវត្ថុបណ្តឹងៈ</u>** ប្តឹងទាមទារដី

បានឃើញបណ្តឹងសាទុក្ខលេខ២៨៧ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះសាត ហៀត ប្តឹងមិនសុខចិត្ត នឹងសាលដីការដ្ឋប្បវេណីលេខ៧៦(ង) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៦០ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៨-០៩-២០០០ របស់ដើមចោទឈ្មោះឡោះ ហាលីម ប្តឹងទាមទារដីទំហំ២៦ម x ១៨ម និងប្តឹងសុំហាមឃាត់មិនឱ្យឈ្មោះរស សាងសង់ផ្ទះនៅភូមិ២ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ដោយអាងហេតុថា ដីនេះ ខ្លួនធ្លាប់កាន់កាប់តាំងពីឆ្នាំ១៩៧៩ មកហើយ ឈ្មោះរស បានដណ្តើមរំលោភយកជាបន្តបន្ទាប់ ។

តាមពាក្យបណ្តឹងតបចុះថ្ងៃទី២៧-១២-២០០១ របស់ចុងចម្លើយឈ្មោះសាត ហៀក ថា ដីមានទំនាស់នេះ ជាដីរបស់ឪពុកខ្លួនឈ្មោះរស បានកាន់កាប់រស់នៅតាំងពីឆ្នាំ១៩៧៩មក មានទំហំ៤៥១ម៉ែត្រការេ ស្ថិតនៅភូមិ៤ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៤៥(ប) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះឡោះ ហាលីម ចុះថ្ងៃទី១៨-០៩-២០០០ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងតបរបស់ចុងចម្លើយឈ្មោះសាត ហៀក ចុះថ្ងៃទី២៧១២-២០០១ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់

៣-ទទួលស្គាល់ការផ្ទេរសិទ្ធិចុះថ្ងៃទី២៣-១០-២០០០ របស់ឈ្មោះរស ឱ្យទៅកូនបង្កើតឈ្មោះសោត ហៀក ជាតំណាង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-ប្រគល់ដីមានទំហំ៤អា ៥១សង្ទិអា ដូចមានក្នុងគំនូសប្លង់ប៊ិចពណ៌ក្រហមជុំវិញរបស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលខណ្ឌឫស្សីកែវ ចុះថ្ងៃទី១៦-០៨-២០០១ នៅភូមិ២+៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ទៅឱ្យឈ្មោះរស ដែលមានឈ្មោះសាត ហៀក ជាតំណាងកាន់កាប់គ្រប់គ្រង ចាប់ពីពេលសាលក្រមនេះចូលជាស្ថាពរ ។

៥-បង្គាប់ឱ្យឈ្មោះឡោះ ហាលីម សងសំណងការខូចខាតសំភារៈសាងសង់ ខូចកិត្តិយស ខាតពេលវេលា និងជម្ងឺចិត្តចំនួន៧លានរៀល ឱ្យទៅឈ្មោះរស ដែលមានតំណាងឈ្មោះសាត ហៀក ។

៦-រឹបអូសប្រាក់ប្រដាប់ក្តីរបស់ដើមចោទឈ្មោះឡោះ ហាលីម គឺពន្ធចុះបញ្ជី និងពន្ធហ្នឹង១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់សាក្សី២០០០រៀល អ្នកប្រគល់ដីកាកោះសរុប ៧.០០០រៀល ដែលដើមចោទបានបង់ទុកជាស្រេច ។

៧-បង្គាប់ឲ្យឈ្មោះឡោះ ហាលីម បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់សាក្សី២០០០៛ អ្នកប្រគល់ដីកាកោះ៣០០០៛ សរុប៧០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់៧.០០០៛ ដែលចុងចម្លើយបានបង់ទុកជា ស្រេច ។

កាលបើសាលក្រមចូលជាស្ថាពរហើយ បង្គាប់ឱ្យឈ្មោះឡោះ ហាលីម សងប្រាក់៧០០០៛ នេះទៅឱ្យឈ្មោះរស វិញនិងបង្គាប់ឱ្យឡោះ ហាលីម ដែលជាអ្នកចាញ់ក្តីបង់ពន្ធសមាមាត្រ១%លើចំនួនទឹកប្រាក់ដែលតុលាការបានសម្រេចឲ្យបង់ដូចចំណុចទី៤+៥ ខាងពន្ធសមាមាត្រនេះ ត្រូវបង់ពេលដែលតុលាការចេញសេចក្តីចម្លងសាលក្រមឲ្យប្រាក់ដែលបានពី ពន្ធសមាមាត្រនេះ ត្រូវបង់ចូលថវិការដ្ឋចំនួន៨០ភាគរយ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០%។ តាមមាត្រា៣, ៧, ១១. ១២, ១៦ នៃច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ០៧ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ ។

៨-សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូភាគី មេធាវីដើមចោទ បើភាគីណាមួយមិនយលព្រមនឹងសាលក្រមនេះ សម្រេចផ្តល់សិទ្ធិឱ្យប្តឹងឧទ្ធរណ៍រយៈពេល ២ខែ គិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះឡោះ ហាលីម ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៤៥(ឋ) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៦(ង) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-០៩-០២ របស់ឈ្មោះឡោះ ហាលីម ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៤៥(ឋ) ចុះថ្ងៃទី០២-០៩-២០០២ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣-ប្រគល់ដីទំនាស់ទំហំ៤អា ៥១សង្ទិអា តាមគំនូសប្លង់ប៊ិចពណ៌ក្រហមជុំវិញរបស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលខណ្ឌឫស្សីកែវ ចុះថ្ងៃទី១៦-០៨-២០០១ ស្ថិតនៅភូមិ២ និងភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ទៅឱ្យឈ្មោះឡោះ ហាលីម ជាដើមចោទ ចាប់ពីពេលសាលដីកានេះ ចូលជាស្ថាពរតទៅ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធហ្នឹង ពន្ធចុះបញ្ជីក្តី២៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ ចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ សរុប១៣.០០០៛ ។ កាលបើផុតរយៈពេលប្តឹងសាទុក្ខបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់១៣.០០០៛ សងទៅដើមចោទវិញ និងបង្គាប់ឱ្យចុងចម្លើយបង់ពន្ធ សមាមាត្រ១% លើតម្លៃដីទំនាស់ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៤៧ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះសាត ហៀត ប្តឹងមិនសុខចិត្ត និងសាលដីការដ្ឋប្បវេណីលេខ៧៦(ង)ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៤ របស់ឈ្មោះសាត ហៀក។

បានឃើញសារណាតបចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៤ របស់ឈ្មោះឡោះ ហាលីម ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះសាត ហៀត នាពេលសវនាការថា : ដីដែលទំនាស់នេះ ខ្លួនបានកាន់កាប់ និងគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩ ដោយមានអាជ្ញាធរដឹងឮនៅភូមិអំឡុង នៃការរស់នៅពុំដែលមានទំនាស់ជាមួយបងប្អូនជិតខាងអ្វីឡើយ ។

***<u>សំណូមពរ:</u>*** -សុំគ្រប់គ្រងដីទំហំ២៦មx១៨ម ជាកម្មសិទ្ធិ ។

-សុំបដិសេធសាលដីកាសាលាឧទ្ធរណ៏ចោល ។

បានស្តាប់ចម្លើយរបស់ឈ្មោះឡោះ ហាលីម នាពេលសវនាការថា : នៅឆ្នាំ១៩៧៩ ខ្លួនបានមករស់នៅលើដីភូមិកំណើតដែលជាដីកេរ្តិ៍មរតក ប៉ុន្តែនៅចុងឆ្នាំ១៩៧៩ លោកឯល វ៉ាន់ណូ បានមកសុំកន្ទុយដីខ្លួនដើម្បីឱ្យប្រជាជនរស់នៅជាបណ្តោះអាសន្ន ចំណែករស រស់នៅក្រុមទី៣ ភូមិ២ ទល់មុខផ្ទះម៉ាត់ សារី ឯណោះ ។

ខ្លួនសុំឱ្យតុលាការកំពូលតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក........... ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា ដីទំនាស់នេះ កូនក្តីខ្លួនកាន់កាប់ និងគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩ រហូតមកពុំដែលបោះបង់ទេ ។

សុំឱ្យតុលាការតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គួភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៤៧ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះសាត ហៀត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលលោករស អះអាងក្នុងសារណាចុះថ្ងៃទី១៧-០៣-២០០៤ ក៏ដូចចម្លើយរបស់សាត ហៀត នាពេលសវនាការនេះថាលោកឡោះ ហាលីម ពុំដែលរស់នៅលើដីទំនាស់នេះទេ នោះគឺជាការពុំត្រឹមត្រូវទេ ពីព្រោះថាៈ

តាមការបំភ្លឺរបស់រដ្ឋអំណាចភូមិ-សង្កាត់ បញ្ជាក់យ៉ាងច្បាស់ថា ដីទំនាស់ពិតជា ដីរបស់ឈ្មោះឡោះ ហាលីម បានចូលមកកាន់កាប់មុនគេ តាំងពីឆ្នាំ១៩៧៩ មកដីនេះស្ថិតនៅក្នុងក្រុម១ ភូមិ២ សង្កាត់ច្រាំងចំរេះ១ មិនមែនក្នុងភូមិ៤ទេ ។ ហើយដីនេះឈ្មោះឡោះ ហាលីម បានដាក់ពាក្យសុំកាន់កាប់ចុះថ្ងៃទី២៦-០៦-១៩៩០ រួចហើយ មានទាំងបង្កាន់ដៃទទួលពាក្យលេខ១២៩៦៩ ចុះថ្ងៃទី២៨-០៧-១៩៩០។

-យល់ឃើញថា តាមរបាយការណ៍លេខ៨៩/៩៩ របក ចុះថ្ងៃទី១៨-០២-៩៩ របស់ចៅសង្កាត់ច្រាំងចំរេះ តាមលិខិតលេខ០៥៥/រ.ប.ក ចុះថ្ងៃទី៣១-០៧-២០០៣ របស់អភិបាលខណ្ឌឬស្សីកែវ បានទទួលស្គាល់ថា ដីទំនាស់គឺឈ្មោះឡោះ ហាលីម ជាអ្នកកាន់កាប់ រីឯបញ្ហាដែលទាក់ទងនឹងការសាងសង់ផ្ទះរបស់ឈ្មោះរស លោកប្រាក់ សុផុន ជាចៅសង្កាត់បាន បំភ្លឺថា ការសុំសាងសង់ផ្ទះនេះខ្លួនមិនទាន់អនុញ្ញាតិទេ ប៉ុន្តែឈ្មោះរស ៖នេះសាងសង់ទោះបីជាមានការប្តឹងជំទាស់ពីឈ្មោះឡោះ ហាលីម ក៏ដោយ ។

- យល់ឃើញថា តាមគំនូសប្លង់ទីតាំងដីទំនាស់ចុះថ្ងៃទី១៦-០៨-២០០១ ដែលយោងតាមគំនូសប្លង់ដែលបានគូស និងចុះហត្ថលេខានៅថ្ងៃទី២០-០៤-២០០០ របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ខណ្ឌឫស្សីកែវ បញ្ជាក់ឱ្យឃើញថា ដីទំនាស់ដែលមានគូសសញ្ញាទឹកប៊ិចក្រហម មិនពាក់ព័ន្ធនឹងដីដែលរស សង់ផ្ទះនោះទេ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧៦(ង) ចុះថ្ងៃទី១៩-០៦-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ និងគតិច្បាប់ហើយ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ២៤៧ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះសាត ហៀក ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៧៦(ង) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ដែលដើមចោទបានបង់នៅតុលាការកំពូលចំនួន១៩.០០០៛ គឺៈ-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥០០០៛ សរុប ១៩.០០០រៀល តម្រូវឱ្យលោករស ដែលមានលោកសាតហៀក ជាតំណាង សងប្រាក់ចំនួន១៩.០០០៛ នេះ ទៅលោកឡោះ ហាលីម និងបង្គាប់ឱ្យឈ្មោះរស ដែលមានឈ្មោះសាត ហៀក ជាតំណាងបង់ពន្ធសមាមាត្រតាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៤ ។